ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤៧៥
ចុះថ្ងៃទី ០៨-៦-២០១១
សាលដីកា
លេខ: ៨០ ក្រIV.អ
ចុះថ្ងៃទី ០២-១២-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំងសកម្មភាពរបស់សាលាជំនុំជំរះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី០២-១២-២០១១ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជំរះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៤៧៥ ចុះថ្ងៃទី ០៨-៦-២០១១ រវាង:

១- ជនជាប់ចោទឈ្មោះ [redacted] អាហ៊ីន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ-ឥស្លាម របររកស៊ីនៅផ្ទះ ទីកន្លែងកំណើតសង្កាត់ច្រាំងចំរេះទី១ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនមាន ។

ត្រូវឃាត់ខ្លួននៅថ្ងៃទី២៥-៩-២០០៩ ឃុំខ្លួនលេខ ២៣៥៤ តព្រ ចុះថ្ងៃទី២៨-៩-២០០៩

២- ជនជាប់ចោទឈ្មោះ [redacted] ហ្វា ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ-ឥស្លាម របររកស៊ីមិនពិតប្រាកដ ទីកន្លែងកំណើតសង្កាត់ច្រាំងចំរេះទី១ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅ



Scanned with CamScanner

[redacted] ឪពុកឈ្មោះ [redacted]

(ı) ម្តាយឈ្មោះ [redacted] (ı) នៅលីវ ទោសពីមុនមាន ។

ត្រូវចោទពីបទៈ ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចមុខសាលារៀនចំរើនរដ្ឋ ផ្លូវជាតិលេខ ៥ សង្កាត់ស្ទាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥-៩-២០០៩ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២៩ឆ្នាំ ទីកន្លែងកំណើតភូមិខ្លី សង្កាត់ជម្ពូវ័ន្ត ស្រុកជុំគីរី ខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ។

## អង្គហេតុ

តាមកំណត់ហេតុបណ្តឹងរបស់ឈ្មោះ [redacted] ភេទស្រី ចុះថ្ងៃទី២៥-៩-២០០៩ ទីលំនៅបច្ចុប្បន្ន [redacted] ដែលជាជនរងគ្រោះបានប្តឹងពីជនល្មើសពីនាក់ជិះម៉ូតូមួយគ្រឿងម៉ាក SuSuki វីវ៉ា ពណ៌ខ្មៅបានបើកពីក្រោយអែបម៉ូតូនាងខ្ញុំ ហើយធ្វើសកម្មភាពឆក់ខ្សែក នាងខ្ញុំ ហើយជនល្មើសបានជិះម៉ូតូគេចខ្លួនបាត់ ខណៈនោះ នាងខ្ញុំ បានឃើញសមត្ថកិច្ចនគរបាលប៉ុស្តិ៍ស្ទាយប៉ាក នាងខ្ញុំបានស្រែកប្រាប់ ចោរឆក់ខ្សែក ដោយចង្អុលទៅជនល្មើសដែលកំពុងជិះម៉ូតូគេចខ្លួន ។ ពេលនោះសមត្ថកិច្ចដេញតាមចំណែកនាងខ្ញុំក៏លើក ម៉ូតូមកផ្ទះ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទៈ

កាលពីថ្ងៃទី២៥-៩-២០០៩ វេលាម៉ោង ៩.៤៥នាទីព្រឹកនៅចំណុចមុខសាលារៀនចំរើនរដ្ឋ ផ្លូវជាតិលេខ ៥ ក្រុម៤ ភូមិលូ សង្កាត់ស្ទាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជនល្មើសឈ្មោះ [redacted] អារីហ៊ីន ភេទប្រុស អាយុ២១ឆ្នាំ និងឈ្មោះ [redacted] រ៉ូហ្សា ភេទប្រុស អាយុ២០ឆ្នាំ បានធ្វើសកម្មភាពឆក់ខ្សែកជនរងគ្រោះឈ្មោះ [redacted] ឡែន ភេទស្រី អាយុ៣០ឆ្នាំ បានសម្រេច។ នៅពេលធ្វើសកម្មភាពជនល្មើសឈ្មោះ [redacted] រ៉ូហ្សា ជាអ្នកបើកម៉ូតូវីវ៉ា ១២៥ ឯឈ្មោះ [redacted] អារីហ៊ីន ជាអ្នកជិះពីក្រោយនឹងជាអ្នកលូកដៃឆក់យកខ្សែកជនរងគ្រោះឈ្មោះ [redacted] ឡែន ។ ក្រោយពេលធ្វើសកម្មភាពបានសម្រេចជនល្មើសទាំងពីរខាងលើក៏ជិះម៉ូតូរត់គេចទៅ តែត្រូវសមត្ថកិច្ចឃាត់ខ្លួនបានជនល្មើសម្នាក់ឈ្មោះ [redacted] អារីហ៊ីន ឯខ្សែកត្រូវបានជនល្មើសបោះចោលដើម្បីបំបាត់កស្តុតាង ។

- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន បានឆ្លើយថា កាលពីថ្ងៃទី២៥-៩-២០០៩ វេលាម៉ោង ៩ព្រឹក ខ្លួនបានជិះម៉ូតូម៉ាក VIVA ១២៥ ចេញពីបឹងកក់ ជាមួយឈ្មោះ រ៉ូហ្សា ដោយឈ្មោះ រ៉ូហ្សា ជាអ្នកឌុបសំដៅទៅផ្ទះខ្លួននៅច្រាំងចំរេះទី១ គីឡូម៉ែត្រលេខ៩ តែជិះដល់ផ្ទះហើយខ្លួនពុំចូលផ្ទះទេ គឺជិះម៉ូតូហួសទៅស្ទាយប៉ាក ដើម្បីដើរលេង លុះដល់មុខសង្កាត់

ស្វាយប៉ាកខ្លួនឃើញនារីជនរងគ្រោះជិះម៉ូតូម៉ាក VIVA អាល់ហ្វា ពណ៌បៃតងជិះបញ្ច្រាសទិស ខ្លួន ពេលនោះឈ្មោះ វ៉ៃហ្វា និយាយថាបើឯងអត់លុយលោះចិញ្ចៀនទៅឆក់ខ្សែកមួយខ្សែទៅ បានហើយ ពេលនោះឈ្មោះ វ៉ៃហ្វា ក៏បានបើកម៉ូតូតាមម៉ូតូនារីរងគ្រោះ រួចអែបក្បែរម៉ូតូនោះ ហើយខ្លួនធ្វើសកម្មភាពឆក់ខ្សែកតែម្តង ។ ខ្សែកនោះថ្លាទីនទម្ងន់ប្រហែលបីជីកន្លះ ក្រោយពី ឆក់រួចខ្លួនបោះចោលបាត់ហើយ ព្រោះខ្លាចប៉ូលីសឆែកកឃើញ ។ ក្រោយពេលឆក់ខ្សែបាន ហើយខ្លួន ក៏ជិះម៉ូតូគេចខ្លួនម្នាក់ឯង ។ ចំណែកអាហ្វា ខ្លួនទម្លាក់វាចោលនៅមុខផ្ទះរបស់វា ។ បន្ទាប់មកសមត្ថកិច្ចក៏បាន ឃាត់ខ្លួនតែម្តង ។ ម៉ូតូដែលខ្លួនធ្វើសកម្មភាពឆក់ខ្សែកនោះ ពុំមែន ជារបស់ខ្លួនទេ គឺជាកម្មសិទ្ធិរបស់យាយខ្លួនឈ្មោះ ជះ ហឿន ។

- តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ឡៃន បានឆ្លើយថា កាលពីថ្ងៃទី២៥-៩-២០០៩ វេលាម៉ោងប្រហែល ១០ព្រឹក ខ្លួនបានជិះម៉ូតូពីរនាក់ឈ្មោះ សៀង ស្រីកា ពីព្រែកពោធិមកផ្ទះខ្លួន នៅភូមិលូ លុះជិះមកដល់សាលារៀនចំរើនរដ្ឋស្ថិតនៅភូមិលូ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ស្រាប់តែមានជនល្មើសពីរនាក់ ជិះម៉ូតូឌុបគ្នា តែខ្លួនពុំស្គាល់ម៉ាកម៉ូតូទេ បាន ឆក់ខ្សែកខ្លួនតែម្តង ខ្សែកនោះផ្លាទីនទម្ងន់បីជីកន្លះ តម្លៃ ៣០០ដុល្លាអាមេរិក ពេលជនល្មើសឆក់ ខ្សែកខ្លួនហើយ ខ្លួនបានដួលទៅលើថ្នល់បណ្តាលឲ្យមានរបួសជើងទាំងសងខាង និងកែងដៃជា ទម្ងន់ ។ ខ្លួនសុំសំណូមពរ សុំទាមទារខ្សែកដែលបានបាត់បង់នោះគ្រប់ចំនួនវិញ ចំពោះជនជាប់ ចោទ សុំឲ្យតុលាការផ្តន្ទាទោសតាមច្បាប់ ។

- តាមចម្លើយសាក្សីឈ្មោះ សៀង ស្រីកា បានឆ្លើយថា នៅថ្ងៃទី២៥-៩-២០០៩ វេលា ម៉ោងជា ៩.១៥នាទីព្រឹក ខ្លួនបានជិះម៉ូតូម៉ាក វ៉េវ ពណ៌ស្លែជាមួយឈ្មោះ [redacted] ឡៃន ទៅផ្សារ ព្រែកភ្នៅ ដើម្បីជួសជុលទូរស័ព្ទដៃ ដោយខូចប្រាក់ជួសជុលបងខ្លួនទាំងពីរនាក់ ក៏ជិះម៉ូតូត្រឡប់ មកផ្ទះវិញ ដោយបងខ្លួនជិះខាងក្រោយ ។ លុះមកដល់ចំណុចជិតរោងចក្រកាត់ដេរទល់មុខសា លារៀនចំរើនរដ្ឋ សង្កាត់ស្វាយប៉ាក ផ្លូវជាតិលេខ ៥ ក៏ស្រាប់តែមានម៉ូតូ ០១គ្រឿង ពុំស្គាល់ម៉ាក ពណ៌ខ្មៅ បើកបរចំនួនពីរនាក់ មកអែបជិតម៉ូតូបងខ្លួន ហើយក៏ធ្វើសកម្មភាពឆក់ខ្សែកពីឈ្មោះ ឡៃន បានសំរេច ប៉ុន្តែម៉ូតូនោះបានមកប៉ះចង្កូតម៉ូតូបងខ្លួនបណ្តាលឲ្យដួល ហើយម៉ូតូដែលឆក់ ខ្សែក បានជិះគេចខ្លួនមកទិសខាងត្បូងសំដៅមកភ្នំពេញ ខ្លួនបានស្គាល់អ្នកដែលអង្គុយក្រោយ គឺពាក់អាវក្រហម ក្រោយមកពេលដែលសមត្ថកិច្ចចាប់ខ្លួនបាន ០១នាក់ គឺម្នាក់ដែលសមត្ថកិច្ច ឃាត់ខ្លួនបាននោះ និងម៉ូតូម៉ាកវ៉េវពណ៌ខ្មៅ ពិតជាបានឆក់ខ្សែកម្នាក់ឈ្មោះ ឡៃន ដែលជិះម៉ូតូ ឌុបខ្លួនប្រាកដមែន ។

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាហ៊ឿន នៅនគរបាលមានលក្ខណៈស៊ី សង្វាក់នឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឡៃន និងសាក្សីឈ្មោះ សៀង ស្រីកា ដែល បញ្ជាក់ឲ្យឃើញជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។



Scanned with CamScanner

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៤ កបពា (ឆ) ចុះថ្ងៃទី០៥-៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចថា:

១- ផ្តន្ទាទោស:

- ឈ្មោះ [redacted] អារីហ៊ីន ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២៨-៩-២០០៩ ។

- ឈ្មោះ [redacted] វ៉ហ្វា ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចសាលារៀនចំរើនរដ្ឋ ផ្លូវជាតិលេខ ៥ សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

២-ប្រគល់ម៉ូតូមួយគ្រឿង ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ របស់តំណាងអយ្យការឲ្យទៅឈ្មោះ ឆះ ហឿន ជាម្ចាស់ដើមវិញ ។

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន និងឈ្មោះ [redacted] វ៉ហ្វា រួមគ្នាសងថ្លៃបាត់បង់ទ្រព្យសម្បត្តិឲ្យទៅឈ្មោះ [redacted] ឡែន ចំនួន ៣០០$ (បីរយដុល្លាអាមេរិក) ជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសាលក្រមចូលជាស្ថាពរ សុំលើសពីនេះបដិសេធចោល ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៧-៤-២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥-៥-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន មេធាវី [redacted] វិសាល កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វ៉ហ្វា បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] អារីហ៊ីន ប្តឹងឧទ្ធរណ៍ ចុះថ្ងៃ១០-ឧសភា-២០១០ ក្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៤១ កបពា (ឆ) ចុះថ្ងៃទី៣០-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចថា:

១-តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៨៤ កបពា "ឆ" ចុះថ្ងៃទី០៥-៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល ។

២-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១០ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ហ្វា មេធាវីការពារសិទ្ធិជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-សាលក្រមនេះត្រូវបាន ឈ្មោះ [redacted] វ៉ហ្វា ប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ក្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ៣១-៨-២០១១ របស់មហាអយ្យការសាលា



Scanned with CamScanner

ឧទ្ធរណ៍ ។

-បានឃើញ របាយការណ៍ ចុះថ្ងៃទី ០៥-០១-២០១១ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍ ។

## **នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] វិហ្សា (អវត្តមាន)
- មេធាវីការពារជនជាប់ចោទលោក [redacted] ចន្ថា (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខ្សៀន (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ រឿងនេះមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វិហ្សា ពីបទ ប្លន់ (ឆក់ខ្សែក) សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤១ កប៣ (ឆ) ចុះថ្ងៃទី៣០-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល ។

មេធាវីលោក [redacted] ចន្ថា ធ្វើសេចក្តីសន្និដ្ឋានថា- ក្នុងរឿងនេះតុលាការបានចោទប្រកាន់ឈ្មោះ [redacted] វិហ្សា ពីបទ ប្លន់ឆក់ខ្សែក គឺជាបទល្មើសជាក់ស្តែងដោយមានសាក្សី និងជនរងគ្រោះបានឆ្លើយបញ្ជាក់នៅតុលាការថា កូនក្តីខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន សុំតុលាការ មេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង ។
- ក្រោយពីបានស្តាប់អំណានចំលើយជនជាប់ចោទ ។
- ក្រោយពីបានស្តាប់អំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ។
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## **សាលាឧទ្ធរណ៍យល់ឃើញថាៈ**

១-បណ្តឹងឧទ្ធរណ៍លេខ ៦៧៨ ចុះថ្ងៃទី០៦-១០-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] វិហ្សា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-មេធាវី [redacted] ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទត្រឹមត្រូវតាមច្បាប់ ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] អារីហ្វីន នៅអធិការដ្ឋាននគរបាលខ័ណ្ឌឫស្សីកែវ (ឯ.១៥) បញ្ជាក់ថា នៅថ្ងៃទី២៥-៩-២០០៩ ម៉ោងប្រហែល ៩ព្រឹក ខ្លួន និង វិហ្សា ជិះម៉ូតូ Viva ១២៥ ពណ៌ខ្មៅចេញពីម្តុំបឹងកក់ទៅផ្ទះនៅគ.មលេខ ៩ ដោយខ្លួនជិះពីក្រោយឆ្ពោះទៅ

លេងស្វាយប៉ាក ផ្លូវជាតិលេខ ៥ ឃើញជនរងគ្រោះជាមនុស្សស្រីជិះម៉ូតូ Wav ឌុបគ្នា២នាក់ ។ អ្នកឌុបមានពាក់ខ្សែក ពួកខ្លួនជិះតាមពីក្រោយដល់មុខរោងចក្រកាត់ដេរឈ្មោះ ហ្វា បើកម៉ូតូពីចំហៀង ហើយខ្លួនលូកដៃស្តាំឆក់ផ្តាច់ខ្សែកបានបណ្តាលឲ្យជនរងគ្រោះដួលម៉ូតូហើយពួកខ្លួនជិះគេចតាមផ្លូវលំមកផ្លូវជាតិលេខ ៥ ទម្លាក់ឈ្មោះ ហ្វា នៅផ្ទះវាំម៉ុំសាលារៀនច្រាំងចំរេះ ។ ឃើញថា ឈ្មោះ [redacted] ហ្វា បានឆក់ខ្សែកជាមួយ [redacted] អាហ៊ីន ពិតមែន ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ១៤១ កប៣ (ឆ) ចុះថ្ងៃទី៣០-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៧៨ ចុះថ្ងៃទី០៦-១០-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហ្វា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤១ កប៣(ឆ) ចុះថ្ងៃទី៣០-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-ឲ្យបន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី...ខែ...ឆ្នាំ ២០១៤.

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner